# យ៉ូស្វេ Joshua

កណ្ឌយ៉ូស្វេប្រាប់អំពីរបៀបដែលជនជាតិអ៊ីស្រាអែលចាប់យកទឹកដីកាណាន ដែលជាទឹកដីដែលព្រះបានសន្យាជាមួយព្ធយុកោរបស់ពួកគេគឺ អ័ប្រាហាំ។ កណ្ឌយ៉ូស្វេ ពួកចៅហ្វាយ សាំយូអែល និងពង្សាវតារក្សត្រកត់ត្រាអំពីប្រវត្តិសាស្ត្រអ៊ីស្រាអែល ចាប់ពីពេលពូជអំបូរទាំងអស់បានមកដល់ទឹកដីសន្យាទៅដល់ការបាត់បង់ទឹកដីជាចុងក្រោយ និងការនិរទេសរបស់យូដាទៅបាប៊ីឡូន។

យ៉ូស្វេស្នងតំណែងពីម៉ូសេជាអ្នកដឹកនាំអ៊ីស្រាអែល។ គាត់ប្រាប់បណ្តាជននូវអ្វីដែលព្រះចង់អោយពួកគេធ្វើ។ ជ័យជំនះរបស់ជនជាតិអ៊ីស្រាអែលពឹងផ្អែកលើការស្តាប់បង្គាប់ព្រះ ជាពិសេសព្រះបន្ទូលរបស់ព្រះ ដែលបានប្រទានតាមរយៈម៉ូសេ។ នៅពេលពួកគេស្តាប់បង្គាប់ នោះពួកគេមានជ័យជំនះ។ ប៉ុន្តែ ជាការសំខាន់ក្នុងការចងចាំថា ពួកគេបានទទួលទឹកដីសន្យាដោយសារសេចក្តីសន្យានិងព្រះគុណរបស់ព្រះ មិនមែនដោយសារការប្រព្រឹត្តល្អរបស់ពួកគេឡើយ។

នៅចុងបញ្ចប់នៃជីវិតរបស់យ៉ូស្វេ គាត់បានប្តេជ្ញាខ្លួនឯង និងគ្រួសាររបស់គាត់ ដើម្បីស្តាប់បង្គាប់ព្រះ ហើយគាត់លើកទឹកចិត្តអោយពូជអំបូរទាំងអស់ធ្វើដូច្នេះផងដែរ។

យ៉ូស្វេគឺជាតួអង្គសំខាន់ ដែលឈ្មោះរបស់គាត់មានន័យថា «ព្រះអម្ចាស់សង្គ្រោះ!»។ នេះគឺជាឈ្មោះដូចគ្នានឹង «យេស៊ូវ» (Jesus) នៅក្នុងព្រះគម្ពីរសញ្ញាថ្មី ដែលឈ្មោះ «យេស៊ូវ» ជាភាសាក្រិកស្មើនឹងឈ្មោះជាភាសាហេព្រើរថា «យ៉ូស្វេ» (Joshua)។

## សារៈសំខាន់នៃកណ្ឌយ៉ូស្វេ Importance of Joshua

ហេតុផលចំបង ដែលកណ្ឌយ៉ូស្វេមានសារៈសំខាន់គឺ កណ្ឌនេះបង្ហាញថា ព្រះបំពេញសំរេចសេចក្តីសន្យារបស់ទ្រង់ជាមួយអ័ប្រាហាំ ដែលពូជពង្សរបស់គាត់នឹងទទួលបានទឹកដីកាណាន។ នេះគឺជាចំនុចដែលយ៉ូស្វេលើកឡើង (១:៦; ២១:៤៥; ២២:៤; ២៣:៥)។ កណ្ឌនេះក៏និយាយអំពីសារៈសំខាន់នៃការស្តាប់បង្គាប់ដើម្បីទទួលទឹកដីជាមរតកផងដែរ (១:៨; ៥:៦; ៧:១-២៦)។ កណ្ឌនេះមានមេរៀនសំខាន់ៗសំរាប់គ្រីស្ទបរិស័ទ ដែលយើងនឹងមើលឃើញនៅខាងក្រោម។

## ប្រវត្តិសាស្ត្រដែលត្រូវបានកត់ត្រាទុកក្នុងកណ្ឌយ៉ូស្វេ History recorded in Joshua

យ៉ូស្វេចាប់ផ្តើមការប្រយុទ្ធរបស់គាត់នៅភាគខាងត្បូងនៃកាណាន ដោយការឡោមព័ទ្ធយេរីខូរ បន្ទាប់ពីបានបញ្ជូនអ្នកស៊ើបការណ៍ទៅយេរីខូរ ដែលមានទីតាំងនៅក្នុងវាលទន្លេយ័រដាន់។ នៅពេលបានចាប់យកយេរីខូរ គាត់វាយប្រហារទីក្រុងអៃយ ដែលមានទីតាំងនៅលើភ្នំខ្ពស់ ប្រហែលជាម្ភៃបួនគីឡូម៉ែត្រពីភាគខាងលិចនៃយេរីខូរ។ គោលដៅច្បាស់បន្ទាប់មកទៀតគឺទីក្រុងគីបៀន ប៉ុន្តែសាសន៍គីបៀនប្រើល្បិចអោយអ៊ីស្រាអែលបង្កើតសន្ធិសញ្ញាសន្តិភាពមួយជាមួយពួកគេ។ នៅក្នុងសន្ធិសញ្ញានេះ អ៊ីស្រាអែលត្រូវវាយប្រហារស្តេចសាសន៍អាម៉ូរីចំនួនប្រាំ។ យ៉ូស្វេធ្វើអោយសាសន៍អាម៉ូរីមានការភ្ញាក់ផ្អើល ដោយការដើរជាក្បួននៅពេលយប់ ដើម្បីវាយប្រហារពួកគេ។ ក្នុងរយៈប៉ុន្មានខែបន្ទាប់មក អ៊ីស្រាអែលបានចាប់យកនិងបំផ្លាញទីក្រុងសំខាន់ៗនៅក្នុងភាគខាងត្បូងនៃកាណាន។

នៅភាគខាងជើង ស្តេចក្រុងហាសោរបាននាំកុលសម្ព័ន្ធមួយចំនួននៅក្នុងកាណានអោយរួបរួមជាមួយគ្នាដើម្បីតស៊ូប្រយុទ្ធជាមួយអ៊ីស្រាអែល ប៉ុន្តែយ៉ូស្វេបំផ្លាញពួកគេនិងទីក្រុងរបស់ពួកគេ។ (ការពិត ជំពូក ១២ ចុះបញ្ជីស្តេចដែលបានបរាជ័យចំនួន៣១អង្គ និងទីក្រុងរបស់ពួកគេ។) អ្នកនិពន្ធកត់សំគាល់ថា ការទាំងនេះបានកើតឡើង ដោយយោងទៅតាមផែនការណ៍របស់ព្រះ។ «ដ្បិតព្រះយេហូវ៉ាទ្រង់បានបណ្តាលចិត្តគេឲ្យរឹងទទឹង ដើម្បីឲ្យគេចេញមកច្បាំងនឹងពួកអ៊ីស្រាអែល ប្រយោជន៍ឲ្យទ្រង់បានបំផ្លាញគេអស់រលីងទៅ ឥតមានប្រណីឡើយ គឺឲ្យលោកបានបំផ្លាញគេ ដូចជាព្រះយេហូវ៉ាបានបង្គាប់មកលោកម៉ូសេ» (១១:២០)។

នៅពេលយ៉ូស្វេឈានដល់ចុងបញ្ចប់នៃជីវិត នៅតែមានផ្នែកជាច្រើននៃទឹកដីសន្យា ដែលត្រូវវាយដណ្តើមយក។ ប៉ុន្តែព្រះណែនាំអោយគាត់បែងចែកទឹកដីដល់ពូជអំបូរនីមួយៗ ទោះបីពួកគេមិនកាន់កាប់ទឹកដីទាំងស្រុងនៅឡើយ។ ដូច្នេះ យ៉ូស្វេបែងចែកទឹកដី ហើយគាត់មានសេចក្តីជំនឿថា នៅថ្ងៃណាមួយអ៊ីស្រាអែលនឹងមានជ័យជំនះទាំងស្រុងមិនខាន។ ការពិត ជ័យជំនះទាំងស្រុងនេះបានកើតឡើងនៅក្នុងរាជ្យរបស់ដាវីឌ។ គឺជាដាវីឌដែលនឹងចាប់យកយេរូសាឡិម ដែលជាតំបន់ការពារចុងក្រោយ ពីពួកយេប៊ូស។

## គម្រោង Outline

អ៊ីស្រាអែលត្រៀមខ្លួនវាយលុកកាណាន (១:១-៥:១២)

ការដណ្តើមបានកាណាន (៥:១៣-១៣:៧)

ការបែងចែកទឹកដី (១៣:៨-២២:៣៤)

អវសានបទ (២៣:១-២៤:៣៣)

## របៀបអានកណ្ឌយ៉ូស្វេ How to read Joshua

កណ្ឌយ៉ូស្វេមានមេរៀនសំខាន់ៗជាច្រើនសំរាប់គ្រីស្ទបរិស័ទ ប៉ុន្តែដើម្បីយល់និងអនុវត្តកណ្ឌនេះបានត្រឹមត្រូវ យើងត្រូវឆ្លើយនឹងសំនួរខាងក្រោមនេះ។

១. តើកណ្ឌយ៉ូស្វេទាក់ទងនឹងកណ្ឌផ្សេងៗទៀតដែលមានក្នុងព្រះគម្ពីរមុនកណ្ឌនេះយ៉ាងដូចម្តេច?

២. តើគោលបំណងរបស់កណ្ឌយ៉ូស្វេសំរាប់អ្នកអានដើមដំបូងក្នុងសម័យព្រះគម្ពីរសញ្ញាចាស់គឺជាអ្វី?

៣. តើកណ្ឌយ៉ូស្វេទាក់ទងនឹងកណ្ឌផ្សេងៗទៀតដែលមានក្នុងព្រះគម្ពីរបន្ទាប់ពីកណ្ឌនេះយ៉ាងដូចម្តេច?

៤. តើកណ្ឌនេះបង្រៀនយើងអ្វីខ្លះអំពីព្រះ?

៥. តើកណ្ឌនេះបង្រៀនយើងអ្វីខ្លះអំពីមនុស្ស?

## ១. តើកណ្ឌយ៉ូស្វេទាក់ទងនឹងកណ្ឌផ្សេងៗទៀតដែលមានក្នុងព្រះគម្ពីរមុនកណ្ឌនេះយ៉ាងដូចម្តេច?

ព្រះគម្ពីរគឺជារឿងធំមួយ ដែលពន្យល់អំពីផែនការរបស់ព្រះចាប់តាំងពីការបង្កបង្កើតដល់ការបង្កបង្កើតថ្មី។ ទ្រង់បានបង្កើតគ្រប់យ៉ាងល្អជាដំបូង ដោយមានអ័ដាមនិងអេវ៉ានៅក្នុងសួនច្បារអេដែន។ ពួកគេគឺជារាស្ត្ររបស់ព្រះ នៅក្នុងទីកន្លែងរបស់ព្រះ ក្រោមការគ្រប់គ្រងនិងព្រះពររបស់ព្រះ។ នេះគឺជាគោលដៅរបស់ព្រះសំរាប់ការបង្កបង្កើត។ ពួកគេ មិនបានស្តាប់បង្គាប់ ហើយត្រូវបានបណ្តេញចេញពីសួនច្បារ ដែលជាទីបរិសុទ្ធរបស់ព្រះ។ កន្លែងផ្សេងៗទាំងអស់ទៀតក្នុងព្រះគម្ពីរនិយាយអំពីផែនការរបស់ព្រះ ក្នុងការសង្គ្រោះមនុស្សចេញពីលទ្ធផលនៃការបះបោរនេះ ហើយស្តានគររបស់ទ្រង់ឡើងវិញ ដែលជារាស្ត្ររបស់ព្រះ នៅក្នុងទីកន្លែងរបស់ព្រះ ក្រោមការគ្រប់គ្រងនិងព្រះពររបស់ព្រះ។ ដូច្នេះ ព្រះបានជ្រើសរើសអ័ប្រាហាំ ហើយបានសន្យាថា ទ្រង់នឹងធ្វើអោយគាត់ក្លាយជាជាតិសាសន៍មួយដ៏ធំ ហើយពួកគេនឹងទទួលបានទឹកដីសន្យា។ តាមរយៈពូជពង្សរបស់អ័ប្រាហាំ ព្រះនឹងប្រទានពរដល់លោកិយ (លោកុប្បត្តិ ១២:៣)។ ពួកគេត្រូវតែជារាស្ត្ររបស់ព្រះ នៅក្នុងទីកន្លែងរបស់ព្រះ ក្រោមការគ្រប់គ្រងនិងព្រះពររបស់ព្រះ។

អ៊ីស្រាអែលបានរង់ចាំអស់រយៈពេលជាយូរមួយសំរាប់សេចក្តីសន្យាទាំងនេះបានសំរេច ពីព្រោះអ៊ីស្រាអែលបានចូលក្នុងទឹកដីសន្យាបួនរយឆ្នាំជាងបន្ទាប់ពីព្រះអង្គបានសន្យាប្រទានទឹកដីអោយពូជរបស់អ័ប្រាហាំ។ (ការរង់ចាំនេះផ្តល់នូវការអនុវត្តមួយសំរាប់គ្រីស្ទបរិស័ទ។ ព្រះបានសន្យាថា ព្រះយេស៊ូវនឹងយាងត្រឡប់មកវិញ ហើយគ្រីស្ទបរិស័ទនឹងទទួលបានការបង្កើតថ្មីជាមរតក។ យើងបានកំពុងរង់ចាំអស់រយៈពេលជាយូរមកហើយ ប៉ុន្តែព្រះនឹងបំពេញសំរេចសេចក្តីសន្យារបស់ទ្រង់ [សូមមើលហេព្រើរ ១១]។ ប្រវត្តិសាស្ត្រទាំងអស់នេះផ្តល់នូវមូលដ្ឋាន

គ្រឹះសំខាន់សំរាប់ការយល់អំពីកណ្ឌយ៉ូស្វេ ពីព្រោះសេចក្តីសន្យារបស់ព្រះគឺជាមូលដ្ឋានគ្រឹះសំខាន់ ដើម្បីអោយពួកគេទទួលបានទឹកដី។

## ២. តើគោលបំណងរបស់កណ្ឌយ៉ូស្វេសំរាប់អ្នកអានដើមដំបូងក្នុងសម័យព្រះគម្ពីរសញ្ញាចាស់គឺជាអ្វី?

ដើម្បីឆ្លើយនឹងសំនួរនេះ យើងត្រូវតែពិចារណាជារួមអំពីគោលបំណងរបស់កណ្ឌយ៉ូស្វេ ពួកចៅហ្វាយ សាំយូអែល និងពង្សាវតារក្សត្រ។ សំខាន់បំផុតនោះគឺ អ្នកនិពន្ធ ចង់បង្ហាញអំពីគោលបំណងរបស់ព្រះនៅក្នុងព្រឹត្តិការណ៍ទាំងអស់នេះ។ ជាពិសេស កណ្ឌយ៉ូស្វេបានបង្រៀនជនជាតិអ៊ីស្រាអែលថា ព្រះបានរក្សាសេចក្តីសន្យារបស់ទ្រង់ជាមួយអ័ប្រាហាំ ហើយពីព្រោះពួកគេមិនបានបណ្តេញជនជាតិកាណានទាំងអស់ចេញពីស្រុកនោះជនជាតិកាណានបានក្លាយទៅជាអន្ទាក់ ឬអង្គប់សំរាប់ពួកគេ (២៣:១៣)។ ដូច្នេះ កណ្ឌនេះបានបង្ហាញក្នុងពេលតែមួយអំពីការចាប់ផ្តើមចូលក្នុងទឹកដីរបស់អ៊ីស្រាអែល និងមូលហេតុដំបូងដែលពួកគេត្រូវបណ្តេញចេញពីទឹកដីជាចុងក្រោយ។ កណ្ឌយ៉ូស្វេផ្តល់សេចក្តីលំអិតច្រើនអំពីការបែងចែកទឹកដី ដែលសំខាន់សំរាប់អ៊ីស្រាអែលដើម្បីអោយពួកគេដឹងជាក់ស្តែងថា ពូជអំបូរណាទទួលបានទឹកដីផ្នែកណា។

## ៣. តើកណ្ឌយ៉ូស្វេទាក់ទងនឹងកណ្ឌផ្សេងៗទៀតដែលមានក្នុងព្រះគម្ពីរបន្ទាប់ពីកណ្ឌនេះយ៉ាងដូចម្តេច?

ព្រះបានសន្យាអ៊ីស្រាអែលថា ពួកគេនឹងបានសេចក្តីសំរាកនៅក្នុងទឹកដី ហើយនៅពេលពួកគេបានយកឈ្នះពួកខ្មាំងសត្រូវរបស់ពួកគេ នោះពួកគេបានសេចក្តីសំរាក (១:១៣; ២២:៤; ២៣:១)។ ប៉ុន្តែកណ្ឌយ៉ូស្វេបង្ហាញថា ជ័យជំនះរបស់ពួកគេមិនបានទាំងស្រុងទេ ហើយកណ្ឌគម្ពីរក្រោយៗមកទៀតបង្ហាញថា ការថ្វាយបង្គំរូបព្រះរបស់អ្នកជិតខាងរបស់ពួកគេបន្តល្បួងនិងបណ្តាលអោយអ៊ីស្រាអែលមានភាពមិនស្មោះត្រង់។

នៅពេលផែនការណ៍របស់ព្រះត្រូវបានបើកសំដែងនៅក្នុងប្រវត្តិសាស្ត្រ ទ្រង់បាននាំសេចក្តីសំរាកដល់អ៊ីស្រាអែល តាមរយៈដាវីឌ នៅពេលដាវីឌបានយកឈ្នះពួកខ្មាំងសត្រូវរបស់ពួកគេ។ ប៉ុន្តែដាវីឌមិនបានផ្តល់សេចក្តីសំរាកចុងក្រោយដល់រាស្ត្ររបស់ព្រះទេ។ សេចក្តីសំរាកពិតប្រាកដបានមកដល់ នៅពេលពូជពង្សដ៏ធំរបស់ដាវីឌ ដែលជាព្រះយេស៊ូវ បានយាងមក។ ព្រះបានប្រទានសេចក្តីសំរាកដល់ពួកគេ តាមរយៈយ៉ូស្វេដែលយកឈ្នះពួកខ្មាំងសត្រូវរបស់ពួកគេ ប៉ុន្តែទ្រង់ប្រទានសេចក្តីសំរាកដល់យើង តាមរយៈព្រះយេស៊ូវដែលយកឈ្នះខ្មាំងសត្រូវដ៏ធំរបស់យើងគឺ សេចក្តីស្លាប់និងសាតាំង។ ព្រះយេស៊ូវប្រទានសេចក្តីសំរាក (ម៉ាថាយ ១១:២៨) ហើយហេព្រើរ ៤:៨ បង្រៀនថា យ៉ូស្វេមិនបានផ្តល់សេចក្តីសំរាកចុងក្រោយទេ ប៉ុន្តែយើងចូលទៅក្នុងសេចក្តីសំរាកនោះ ដោយការជឿលើដំណឹងល្អរបស់ព្រះយេស៊ូវ ហើយយើងត្រូវតែខិតខំចូលទៅក្នុងសេចក្តីសំរាករបស់ព្រះ ដែលយើងនឹងទទួលបាននៅស្ថានសួគ៌នៅចុងក្រោយ។

ព្រះគម្ពីរសញ្ញាថ្មីបានប្រើរឿងអំពីរ៉ាហាប ដើម្បីបង្រៀនមនុស្សនៅសព្វថ្ងៃនេះ។ រ៉ាហាបបានរស់នៅក្នុងចំណោមមនុស្សមួយក្រុម ដែលស្ថិតនៅក្រោមការវិនិច្ឆ័យរបស់ព្រះ ហើយនឹងប្រឈមមុខនឹងថ្ងៃជំនុំជំរះ។ ប៉ុន្តែនាងបានស្តាប់ឮអំពីអ្វី ដែលព្រះបានធ្វើសំរាប់អ៊ីស្រាអែល ហើយបានជឿដល់ព្រះរបស់អ៊ីស្រាអែល និងបានបង្ហាញសេចក្តីជំនឿតាមរយៈសកម្មភាពរបស់នាង។ នៅពេលអ៊ីស្រាអែលកំពុងចូលទៅក្នុងទឹកដីសន្យា មានសំនួរធំមួយថា «តើសាសន៍ទាំងប៉ុន្មានដែលកំពុងរស់នៅទីនោះមានសេចក្តីសង្ឃឹមនឹងរួចពីការវិនិច្ឆ័យរបស់ព្រះដែរឬទេ?» រឿងអំពីរ៉ាហាបបង្ហាញប្រាប់ចំលើយថា ពិតជាមានសង្ឃឹម ប្រសិនបើពួកគេមានជំនឿលើព្រះរបស់អ៊ីស្រាអែល។ នៅក្នុងទីក្រុងយេរីខូរទាំងមូលមានតែស្រីសំផឹងម្នាក់និងគ្រួសាររបស់នាងប៉ុណ្ណោះ ដែលបានសង្គ្រោះ។ ហេព្រើរ ១១:៣១ បង្ហាញថា សកម្មភាពរបស់រ៉ាហាបបានចេញពីសេចក្តីជំនឿ នាងបានសង្គ្រោះដោយសារសេចក្តីជំនឿ ហើយនេះគឺជាការលើកទឹកចិត្តដល់យើងថា លោកិយនេះដែលកំពុងប្រឈមមុខនឹងថ្ងៃជំនុំជំរះរបស់ព្រះ អាចគេចផុតពីសេចក្តីវិនាសតាមរយៈសេចក្តីជំនឿផងដែរ គឺជឿលើដំណឹងល្អរបស់ព្រះគ្រីស្ទ។ ដូច្នេះ ការអនុវត្តចេញពីរឿងអំពីរ៉ាហាបគឺ ត្រូវតែមានសេចក្តីជំនឿលើព្រះគ្រីស្ទ។ អ្នកនិពន្ធក្នុងព្រះគម្ពីរសញ្ញាថ្មីសរសេរការអនុវត្តនេះចេញពីរឿងអំពីរ៉ាហាប។

## ៤. តើកណ្ឌនេះបង្រៀនយើងអ្វីខ្លះអំពីព្រះ?

តាមការរៀបរាប់ខាងលើ យើងមើលឃើញកណ្ឌយ៉ូស្វេបង្រៀនថា៖

- ព្រះយេហូវ៉ា ដែលជាព្រះរបស់អ៊ីស្រាអែល គឺជាព្រះពិតតែមួយ។
- ព្រះស្មោះត្រង់ចំពោះសេចក្តីសន្យារបស់ទ្រង់។
- ព្រះហៅយើងអោយទុកចិត្តនិងស្តាប់បង្គាប់ ហើយតម្រូវឲ្យយើងមានការប្តេជ្ញាចំពោះទំនាក់ទំនងសម្ព័ន្ធមេត្រីរបស់យើងជាមួយព្រះអង្គ (២២-២៤)។
- ព្រះប្រយុទ្ធជំនួសរាស្ត្ររបស់ទ្រង់។
- ព្រះអាចអនុញ្ញាតអោយពួកអ្នកបះបោរប្រឆាំងរស់នៅលើផែនដីរយៈពេលយូរមួយ ប៉ុន្តែនៅចុងបញ្ចប់ព្រះនឹងវិនិច្ឆ័យ ហើយដាក់ទណ្ឌកម្មពួកគេ។
- ព្រះមានសេចក្តីមេត្តាករុណាសូម្បីតែចំពោះស្រីសំផឹង ដោយសារសេចក្តីជំនឿរបស់នាងលើអ្វីដែលនាងបានស្តាប់ឮអំពីព្រះជាម្ចាស់។
- ព្រះចង់អោយមនុស្សស្តាប់បង្គាប់តាមព្រះបន្ទូលរបស់ទ្រង់ ហើយទ្រង់នឹងវិនិច្ឆ័យអស់អ្នកណាដែលមិនស្តាប់បង្គាប់។

- ព្រះគ្រប់គ្រងលើប្រវត្តិសាស្រ្តរបស់មនុស្សជាតិដោយព្រះបន្ទូលរបស់ទ្រង់។ ព្រឹត្តិការណ៍ទាំងប៉ុន្មាន ដែលត្រូវបានកត់ត្រាទុក គឺជាសកម្មភាពរបស់ព្រះនិងបំពេញសំរេចសេចក្តីសន្យា និងព្រះបន្ទូលព្រមានដែលទ្រង់បានប្រទានអោយជាច្រើនសតវត្សមុន។

## ៥. តើកណ្ឌនេះបង្រៀនយើងអ្វីខ្លះអំពីមនុស្ស?

- មនុស្សបានបះបោរប្រឆាំងនឹងព្រះ ហើយសមនឹងទទួលទណ្ឌកម្មពីទ្រង់។
- សូម្បីតែរាស្រ្តរបស់ព្រះក៏បានព្រងើយកន្តើយចំពោះព្រះបន្ទូលរបស់ព្រះដែរ។
- មនុស្សខ្លះនឹងមានសេចក្តីជំនឿ ហើយបង្ហាញសេចក្តីជំនឿនោះដោយការប្រព្រឹត្ត។
- ទោះបីជាព្រះគ្រប់គ្រងលើប្រវត្តិសាស្រ្តដោយអំណាចព្រះចេស្តាក៏ដោយ ក៏យើងនៅតែទទួលខុសត្រូវចំពោះសកម្មភាពរបស់យើងដែរ។